# វិធីបង្រៀនទូទៅនៅបឋមសិក្សាក្នុងសម័យសង្គមរាស្ត្រនិយម

*ដោយៈ* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ប្រទេសខ្មែរ ក្រោយពេលទទួលបានឯករាជ្យថ្ងៃ៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ បានចាប់រីកលូតលាស់ ហាក់ដូចជាមានទឹកអម្រឹត បង្ហូរចុះមកស្រោចស្រពទឹកដី ដែលហួតហែងរីងរៃអស់កាលជាច្រើនសតវត្សមកហើយ។ សមិទ្ធផលធំៗគ្រប់វិស័យ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌បានផុសឡើងត្រដែតគ្រប់ទិសទី ពាសពេញព្រះរាជាណាចក្រកម្ពុជា។ នៅពេលនោះ សន្ទុះទឹកចិត្តសប្បាយរីករាយ ចំពោះការរៀនសូត្ររបស់ប្រជាពលរដ្ឋមានទំហំធំធេងណាស់។ គ្រប់ស្រុក គ្រប់ឃុំ មានសមាគមទ្រទ្រង់ សាលារៀនបង្កើតដោយព្រះសង្ឃនិងមាតាបិតាសិស្ស។ គេនាំគ្នាធ្វើបុណ្យផ្កា រៃបច្ច័យមកកសាងសាលារៀន នៅក្នុងភូមិ ឃុំរបស់ខ្លួនទាំងបឋមសិក្សា ទាំងមធ្យមសិក្សាបានរីកដុះដាលដូចផ្សិត ត្រូវទឹកភ្លៀង។ ដើម្បីឆ្លើយតបនឹងតម្រូវការគ្រូបង្រៀន ក្រសួងអប់រំជាតិ បានបង្កើតមជ្ឈមណ្ឌលគរុកោសល្យទន្ទេបាទី នៅឆ្នាំ១៩៥៥ មជ្ឈមណ្ឌលគរុកោសល្យកំពង់កន្ទួតនៅឆ្នាំ១៩៥៧ និងវិទ្យាស្ថានជាតិគរុកោសល្យ នៅឆ្នាំ១៩៥៨។ មជ្ឈមណ្ឌលគរុកោសល្យ និងវិទ្យាស្ថានជាតិគរុកោសល្យទាំងនេះ បណ្តុះបណ្តាលគ្រូជាច្រើនជំនាន់ រហូតដល់មុនឆ្នាំ១៩៧៥។*

*វិធីបង្រៀនទូទៅ បានរីកចម្រើនយ៉ាងខ្លាំងក្លាហើយ នៅសម័យនោះ។ នៅឆ្នាំ១៩៥៥ លោក ចេត្រ ឆែម ដែលជាអធិការបឋមសិក្សាដ៏ល្បីល្បាញមួយរូប បានបោះពុម្ពសៀវភៅមួយ ដែលមានចំណងជើងថា «**សេចក្តីណែនាំគ្រូបង្រៀននៅសាលាបឋមសិក្សា**»។ សៀវភៅនេះ ចែកជាពីរផ្នែកគឺ*

-ផ្នែកទីមួយមានខ្លឹមសារថា ‹របៀបរៀបចំកន្លែងរៀន-វិន័យរបស់សិស្ស›

-ផ្នែកទី២ និយាយអំពីវិធីបង្រៀន ទៅតាមមុខវិជ្ជាផ្សេងៗ។

ក្នុងផ្នែកទី១ លោកមានការណែនាំជាច្រើនដល់គ្រូបឋមសិក្សាយើង ដូចជាការបំបែកសិស្សទៅតាមថ្នាក់ ការរៀបចំសិស្សក្នុងថ្នាក់ ករណីកិច្ចរបស់សិស្សដែលនៅក្នុងថ្នាក់ និងទណ្ឌកម្ម។ សេចក្ដីណែនាំនេះ ជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយ សម្រាប់គ្រូបឋមសិក្សាយកទៅអនុវត្តនៅក្នុងវិជ្ជាជីវៈរបស់ខ្លួន។

ម្យ៉ាងវិញទៀត ដូចយើងបានជ្រាបស្រាប់ហើយ វិធីសាស្ត្របង្រៀនទាំងនោះ សុទ្ធតែបានផ្សព្វផ្សាយចេញអំពីសាលាគរុកោសល្យ មាន៖

-មជ្ឈមណ្ឌលគរុកោសល្យទន្លេបាទី

-មជ្ឈមណ្ឌលគរុកោសល្យ កំពង់កន្ទួត

-មហាវិទ្យាល័យគរុកោសល្យ។

នៅក្នុងឯកសារ វគ្គបណ្ដុះបណ្ដាលវិក្រឹតការគរុកោសល្យនៃមជ្ឈមណ្ឌលគរុកោសល្យកំពង់កន្ទួតដែលបានរៀបចំឱ្យបោះពុម្ព ដោយមានការឧបត្ថម្ភពីយូនីសេហ្វ (UNICEF) នៅឆ្នាំ១៩៦៦នោះ សៀវភៅនេះត្រូវបានគេបែងចែកជាបីចំណែកគឺ

-គរុកោសល្យទូទៅ

-គរុកោសល្យអនុវត្ត

-ចិត្តវិទ្យាអនុវត្ត។

នៅក្នុងផ្នែកទីមួយ ដែលស្ដីអំពីគរុកោសល្យទូទៅនិងផ្នែកទីបី ចិត្តវិទ្យាអនុវត្ត ជាផ្នែកដ៏សំខាន់ៗបំផុត ដែលនៅសម័យក្រោយៗមក ដូចជា សម័យកាលក្រោយការបោះឆ្នោតជាសកលឆ្នាំ១៩៩៣ គឺនៅក្រោយពេលដែលខ្មែរយើង បានរួមរួមគ្នាសាជាថ្មី ដើម្បីធ្វើការឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដោយសេរី និងដោយមានពហុបក្សចូលរួម ព្រមទាំងបានវិលទៅកាន់របបរាជានិយមឡើងវិញ។ គេបានបកប្រែយកឯកសារនោះ ពីភាសាបារាំង មកជាភាសាខ្មែរ សម្រាប់យកមកបង្រៀន នៅតាមសាលាគរុកោសល្យនានា ដោយគ្រាន់តែបន្ថែម ឬបន្ថយខ្លឹមសារបន្តិចបន្តួច ដើម្បីឱ្យសមស្របទៅនឹងសម័យកាលរបស់សង្គម។

ចំណុចសំខាន់ៗនៃគរុកោសល្យទូទៅ នៅក្នុងផ្នែកទីមួយ គឺវិធីបង្រៀនទូទៅ។ តើអ្វីទៅដែលគេ ហៅថាវិធីបង្រៀន?

**វិធីបង្រៀន**(Les Méthodes; Teaching Methods) *គឺជាមធ្យោបាយ ឬមាគ៌ាយ៉ាងខ្លីដែលនាំឱ្យការបង្រៀនមួយ ទទួលបានលទ្ធផលល្អ។*

***វិធីសាស្ត្រ*** *គឺជាការសិក្សាជាប្រព័ន្ធអំពីវិធីទាំងឡាយ ដែលត្រូវបានអនុវត្ត នៅក្នុងមុខវិជ្ជាមួយ។*

*នៅក្នុងសម័យសង្គមរាស្ត្រនិយម គេបានបែងចែកវិធីបង្រៀនជាពីរផ្នែកគឺ វិធីអនុមានរួម និងវិធីអនុមានញែក។*

**១-វិធីអនុមានរួម** (Méthode inductive)

*វិធីអនុមានរួម គឺជាវិធីមួយ ដែលគេបង្រៀនផ្ដើមចេញពីឧទាហរណ៍ ពីការត្រិះរិះពិចារណា ដើម្បីទៅដល់គោលការណ៍ ឬច្បាប់ទូទៅ។*

*ជាឧទាហរណ៍ ក្នុងការបង្រៀនអំពីនិយមន័យរបស់នាម គ្រូអាចសួរសំណួរបំផុសដល់សិស្សក្នុងថ្នាក់រៀន ដើម្បីទាញយកនិយមន័យដូចជា តើប្អូនបានឃើញអ្វីខ្លះ តាមផ្លូវធ្វើដំណើរពីផ្ទះរបស់ប្អូន មកដល់សាលារៀន?*

*តាមរយៈសំណួរខាងលើនេះ គ្រូអាចសួរសិស្សជាបន្តបន្ទាប់ ដើម្បីទទួលយកចម្លើយពីសិស្ស។ ចម្លើយរបស់សិស្ស អាចមានដូចជា មាន់ ទា ជ្រូក កង់ ដូង ស្វាយ ផ្ទះ សុក រថយន្ត សៅ ធីតា សុជាតា ត្រី តុលាការ ធនាគារ រោងភាពយន្ត គោ ម៉ូតូ កុក សេះ ទូរស័ព្ទ ចេក អំពៅ តុ កៅអី ហាងទំនិញ គ្រប់មៀន ស្លែ ត្រសក់ សណ្ឋាគារ សន្តិភាព យុត្តិធម៌ យានដ្ឋាន។ល។*

*គ្រូគួរតាពាងលើក្ដារខៀនមុនពេលសួរសិស្ស ឬក្រោយពេលសួរសិស្សក៏បាន អាស្រ័យទៅតាម ល្បិចបង្រៀនផ្ទាល់ខ្លួន។ ប៉ុន្តែ ជាការប្រសើរ គ្រូគួរតែគូរតារាងឱ្យបានរួចជាស្រេចមុនសួរសំណួរដល់សិស្ស។ បន្ទាប់មក គ្រូជ្រើសរើសចម្លើយសិស្សដាក់ក្នុងតារាងខាងក្រោម៖*

| | | | | | |
|---|---|---|---|---|---|
| សុក សៅ ធីតា សុជាតា | មាន់ ទា ជ្រូក ត្រី គោ កុក សេះ | ដូង ចេក ស្លែ ស្វាយ អំពៅ ត្រសក់ | កង់ រថយន្ត ម៉ូតូ ទូរស័ព្ទ តុ កៅអី | ផ្ទះ តុលាការ ធនាគារ រោងភាពយន្ត ហាងទំនិញ សណ្ឋាគារ យានដ្ឋាន | សន្តិភាព យុត្តិធម៌ |

*ក្នុងការជ្រើសរើសចម្លើយសិស្សដាក់ក្នុងតារាង គ្រូត្រូវដាក់ឱ្យចំគោលដៅ ដែលខ្លួនចង់បាន។ ប៉ុន្តែ តារាងខាងលើនេះ គ្រូមិនចាំបាច់បំពេញក្បាលតារាងទេ ពីព្រោះ គ្រូត្រូវសួរបំ ផុសបន្តទៀត ដើម្បីទាញយកនិយមន័យ។*

*បន្ទាប់មកទៀត គ្រូឱ្យសិស្សពិនិត្យមើលប្រអប់នីមួយៗ វាឈ្មោះអ្វីខ្លះ។ គ្រូចាប់ផ្ដើមប្រើពាក្យ ឈ្មោះ ដើម្បីឱ្យសិស្សចាប់*

*អារម្មណ៍លើពាក្យនេះ។ ក្រោយពេលសួរបំផុសបានហើយ ទើបគ្រូបំពេញ ក្បាលតារាង ដូចខាងក្រោម៖*

| មនុស្ស | សត្វ | រុក្ខជាតិ | វត្ថុ | | ទីកន្លែង | គំនិត |
|---|---|---|---|---|---|---|
| សុក សៅ ធីតា សុជាតា | មាន់ ទា ជ្រូក ត្រី គោ កុក សេះ | ដូង ចេក ស្ពៃ ស្វាយ អំពៅ ត្រសក់ | កង់ រថយន្ត ម៉ូតូ ទូរស័ព្ទ តុ កៅអី | | ផ្ទះ តុលាការ ធនាគារ ពេង ភាពយន្ត ហាងទំនិញ ... | សន្តិភាព យុត្តិធម៌ |

*ក្រោយពេលគ្រូ បានបំពេញក្បាលតារាងរួចហើយ ទើបគាត់ចាប់ផ្តើមសួរសំណួរបំ ផុសរកខ្លឹមសារនៃចម្លើយ៖ តើនាមជាអ្វី?*

*សិស្ស ចាប់ផ្តើមពិនិត្យមើលតារាងម្តងទៀត ទើបឆ្លើយសំណួរគ្រូ។ ជាទូទៅចម្លើយរបស់សិស្ស ពិតជាមិនទាន់ត្រឹមត្រូវទាំងស្រុងទេ។ ដូច្នេះ គ្រូត្រូវចេះជួយកែលម្អសិស្ស ដើម្បីស្រេចបាននិយមន័យ ជាចុងក្រោយ៖*

*នាម ជាឈ្មោះរបស់មនុស្ស សត្វ រុក្ខជាតិ ទីកន្លែង វត្ថុ និងគំនិត។*

*ក្រៅពីការប្រើប្រាស់ល្បិចបង្រៀនតាមវិធីអនុមានរួមជាក្រុមធំក្នុងថ្នាក់រៀនទាំងមូល គ្រូក៏អាច បង្រៀនល្បិចនេះ តាមក្រុមតូចផងដែរ តាមការបែងចែកសិស្សជាក្រុមតូច ដែលមានគ្នាចំនួន៣ ឬ៤ នាក់ បន្ទាប់មក គ្រូបែងចែកតារាង ដែលមានបំពេញក្បាលតារាងជាស្រេច រួចទើបឱ្យសិស្សក្នុងក្រុម ខិតខំរកពាក្យ ដែលមានន័យត្រូវនឹងក្បាលតារាង តាមការប្រឡងប្រណាំង តើក្រុមណារកពាក្យបាន ច្រើនជាងគេ ដោយគ្រូមិនភ្លេចកំណត់ពេលវេលាឱ្យបានត្រឹមត្រូវ រួចហើយទើបគ្រូចាប់ផ្តើមសួរសំណួរបំផុសរកនិយមន័យជាលើកចុងក្រោយ។*

**២- វិធីអនុមានញែក** ( Méthode déductive )

*វិធីអនុមានញែក គឺជាវិធីមួយ ដែលគេបង្រៀនផ្តើមចេញពីច្បាប់ទូទៅ ដើម្បីទៅដល់ហេតុការណ៍ពិសេស។*

*ជាឧទាហរណ៍ ដើម្បីបង្រៀនអំពីនិយមន័យរបស់នាម គ្រូចាប់ផ្តើមបង្រៀនដោយផ្តល់និយមន័យអំពីនាមឱ្យសិស្សជាមុន បន្ទាប់មកទើបសួរសិស្សឱ្យរកឧទាហរណ៍ជាក្រោយ។*

នាម ជាឈ្មោះរបស់មនុស្ស សត្វ រុក្ខជាតិ ទីកន្លែង វត្ថុ និងគំនិត។

ចម្លើយរបស់សិស្ស អាចមានដូចជា មាន់ ទា ជ្រូក កង់ ដូង ស្វាយ ផ្ទះ សុក រថយន្ត សៅ ធីតា សុជាតា ត្រី តុលាការ ធនាគារ ពេងភាពយន្ត គោ ម៉ូតូ កុក សេះ ទូរស័ព្ទ ចេក

អំពៅ តុ កៅអី ហាង ទំនិញ ត្រប់ មៀន ស្ដែ ត្រសក់ សណ្ឋាគារ សន្តិភាព យុត្តិធម៌ យាន ដ្ឋាន សុខា ក្វាន ក្របី ផ្ដែ ផ្សារ ចចក។ល។

វិធីទាំងពីរខាងលើនេះ អាចប្រើប្រាស់បាន តាមទម្រង់ច្រើនយ៉ាង៖

**-វិធីរាយរ៉ាប់** (Méthode expositive)

ក្នុងវិធីនេះ គ្រូនិយាយពន្យល់តែម្នាក់ឯង ចំណែកសិស្សវិញនៅស្ងៀម គ្មាននិយាយ ឆ្លងឆ្លើយអ្វីទាំងអស់ គឺចាំតែស្ដាប់គ្រូពន្យល់។ វិធីនេះ គ្មានការប្រើប្រាស់ការពិចារណារបស់សិស្សឡើយ ហើយការបង្រៀន ប្រព្រឹត្តទៅយ៉ាងស្ងៀមស្ងាត់។ គេប្រើវិធីនេះ សម្រាប់សិស្សថ្នាក់ខ្ពស់។

**-វិធីសន្ទនា** ( Méthode interrogative )

ក្នុងវិធីនេះ គេដឹកនាំមេរៀន តាមរបៀបការជជែកគ្នា។ សិស្សធ្វើការត្រិះរិះពិចារណា ឆ្លើយឆ្លង ដែលធ្វើឱ្យកុមារ មានការប្រុងប្រយ័ត្នជានិច្ច។

ថ្វីបើវិធីសន្ទនានេះ មានចំណុចល្អក្ដី ក៏វាមានគុណវិបត្តិ (Inconvénients) របស់វាដែរ។ ការប្រើវិធីនេះ ធ្វើឱ្យការបង្រៀនប្រព្រឹត្តទៅដោយយឺតយ៉ាវ ហើយពុំបានពេញលេញថែមទៀតផង។

**-វិធីចម្រុះ** ( Méthode mixte )

វិធីនេះ គឺជាគួបផ្សំ វិធីទាំងពីរខាងលើ គឺវិធីរាយរ៉ាប់ និងវិធីសន្ទនា។ គ្រូ ចោទសួរសិស្សផង និងពន្យល់ផង។ មេរៀន ប្រព្រឹត្តទៅជារបៀបការពិភាក្សាគ្នា សិស្សស្ដាប់ផង និយាយផង។ វិធីនេះ ប្រើបាននៅគ្រប់ថ្នាក់ ចាប់ពីថ្នាក់ទាប ដល់ថ្នាក់ខ្ពស់។

វិធីចម្រុះ ជាវិធីមួយ ដែលគេចាត់ទុកថា មានប្រយោជន៍ច្រើនព្រោះ៖

វិធីចម្រុះ ពុំមែនជាវិធីបង្រៀន ដែលចាប់ពញ្ញាត់ខួរក្បាលសិស្ស ដូចវិធីដទៃទៀតឡើយ។ វាធ្វើឱ្យសតិបញ្ញាសិស្ស ឬកុមាររីកចម្រើនជាលំដាប់ ហើយធ្វើឱ្យសិស្សត្រេងត្រាប់មេរៀន ដោយសប្បាយរីករាយ។ គ្រូអាចស្ដាប់ចិត្តគំនិតសិស្ស បានជាក់លាក់ ហើយនាំឱ្យការបង្រៀនរបស់ខ្លួន យោងទៅតាមកម្រិតបញ្ញាសិស្ស។ វិធីនេះ ទម្លាប់ឱ្យសិស្សចេះជួយចាត់ចែង ចេះអារកាត់ឧបសគ្គផ្សេងៗ ដែលវាជួបប្រទះ សម្រាប់ខ្លួនវាផង ហើយសម្រាប់ញាតិមិត្តជិតខាងវាផង។ ក្រៅពីនេះ វាទម្លាប់ឱ្យក្មេងចេះរួមរស់ នៅក្នុងសង្គមផងដែរ។

វិធីអនុមានរួម និងអនុមានញែក ជាវិធីដ៏សំខាន់មួយ ក្នុងវិធីសំខាន់ផ្សេងៗទៀត នៅក្នុង ការបង្រៀនគ្រប់មុខវិជ្ជា ដែលគេមិនអាចបោះបង់ចោលបាន ជាពិសេស នៅក្នុងការបង្រៀនគណិតវិទ្យាជាដើម។ ទោះជាយ៉ាងនេះក្ដី នៅសម័យកាលនោះ គេបានចែកវិធីបង្រៀនតែពីរប៉ុណ្ណោះ ព្រមទាំង មិនបាន

*សិក្សាឱ្យល្អិតល្អន់ ជាក់លាក់ ច្បាស់លាស់ ទៅលើចំណុចខ្លាំង នៅក្នុងវិធីនីមួយៗទេ។ គេមិនបានវែកញែករកចំណុចអាក្រក់ និងផ្តល់ឧទាហរណ៍ ឱ្យបានគ្រប់ជ្រុងជ្រោយដែរ ហើយគេក៏មិនបាន ស្វែងរកវិធីដោះស្រាយបញ្ហាលំបាកទាំងនេះផងដែរ។ នេះជាកង្វះខាតមួយ ដែលគួរឱ្យកត់សម្គាល់ និង មិនអាចមើលរំលងបាន។*

*បន្ទាប់ពីវិធីបង្រៀននេះ ក៏មានការសិក្សាពីល្បិចបង្រៀនផងដែរ។ តើអ្វីទៅដែលហៅថា ល្បិចបង្រៀន?*

## ៣-ល្បិចបង្រៀន

**( Procédés d'enseignement )**

### និយមន័យ

*ល្បិចបង្រៀន គឺជាមធ្យោបាយជាក់ស្តែង ដែលគ្រូប្រើ ដើម្បីអនុវត្តវិធីបង្រៀនមួយ។*

*ឧទាហរណ៍ៈ នៅក្នុងការបង្រៀនអំពីសំណេរ គ្រូអាចប្រើប្រាស់ល្បិចជាច្រើនដូចជា ការប្រើប្រាស់អក្សរចល័ត ការប្រើប្រាស់ក្តារឆ្នួន ការឱ្យសិស្សសរសេរក្នុងខ្យល់។*

*ល្បិចបង្រៀន មានច្រើន និងប្លែកៗរាប់មិនអស់។ គ្រូបង្រៀនម្នាក់ អាចបង្កើតល្បិចថ្មីស ម្រាប់ការប្រើប្រាស់ដោយខ្លួនឯង។ វិធីបង្រៀនទាំងអស់ មិនសុទ្ធតែល្អទាំងអស់នោះទេ។ ល្បិចបង្រៀនមួយចំនួនធ្វើតាមទម្លាប់ដដែលៗ ដូចគ្រឿងយន្តដែលគួរតែជៀសវាង ដូចជាឱ្យសិស្សទន្ទេញមេរៀន ចាំមាត់ ដោយគ្មានពន្យល់។ម្យ៉ាងទៀត គេអាចនិយាយបានថា ល្បិចបង្រៀនល្អ អាស្រ័យដោយគ្រូចេះប្រើប្រាស់។*

*ក្នុងការបង្រៀនសិស្ស នៅសម័យនោះ គេនិយមប្រើល្បិចអព្ភន្តរញាណ៣ប្រភេទ គឺ អព្ភន្តរញាណឥន្រ្ទីយ អព្ភន្តរញាណបញ្ញា និងអព្ភន្តរញាណសីលធម៌។ ដូច្នេះ ចំពោះគ្រូ គួរជៀសវាងការនិយាយបូរបាច់ឥតប្រយោជន៍ និងគួរឱ្យធុញទ្រាន់ ដោយហេតុថា ការបង្រៀនផ្តល់តែទ្រឹស្តីតាមសៀវភៅ គ្មានបានផលអ្វីក្រៅពីធ្វើឱ្យតប់ប្រមល់ក្នុងខួរក្បាលសិស្សឡើយ។ គ្រូអាចអនុវត្តល្បិចអព្ភន្តរញាណតាម របៀបច្រើនយ៉ាងដូចជា ការប្រើប្រាស់វត្ថុ ការប្រើប្រាស់កាយវិការ គ្រាប់ ការប្រើឧទាហរណ៍...។ល។ ក្រៅពីនេះ គេ ក៏បានប្រើល្បិចប្រើប្រាស់សំណួរផងដែរ ព្រោះថា ការចោទសួរជាល្បិច ដែលត្រូវបានប្រើ ប្រាស់ច្រើនជាងគេ។ គ្រូត្រូវយល់ដឹងពីសារៈសំខាន់នៃសំណួរ រូបភាពនៃសំណួរ របៀបចោទសួរ។ ល្បិចសំខាន់មួយទៀត គឺ ល្បិចប្រើក្តារឆ្នួន។ ល្បិចនេះ តម្រូវឱ្យគ្រូចោទសួរសិស្សទាំងអស់គ្នា ហើយគ្រូ ក៏អាចទទួលបានចម្លើយ ពីសិស្សទាំងអស់គ្នា នៅក្នុងពេល*

តែមួយដែរ។ ការប្រើប្រាស់ល្បិចនេះ ទាមទារឱ្យគ្រូមានការប្រុងប្រយ័ត្ន ដោយហេតុថា បើគ្រូតពិនិត្យមិនបានដិតដល់ទេ វានឹងធ្វើឱ្យបាត់សណ្ដាប់ ធ្នាប់ នៅក្នុងថ្នាក់រៀន ពិសេសនៅពេលសិស្សលើកក្ដារឆ្នួន ដើម្បីឱ្យគ្រូពិនិត្យលទ្ធផល។ ល្បិចនេះ គ្រូ ត្រូវប្រើក្នុងរយៈពេលខ្លី មិនត្រូវអូសបន្លាយទេ ព្រោះនាំឱ្យបាត់ប្រសិទ្ធភាព និងសណ្ដាប់ធ្នាប់នៅក្នុងថ្នាក់រៀនទាំងមូល។

បើយោងទៅតាមខ្លឹមសារខាងលើនេះ គេអាចយល់បានថា វិធីបង្រៀនជាមធ្យោបាយមួយជាគោល ដែលគ្រូត្រូវចេះ។ វិធីបង្រៀនបង្កើតឡើងដោយអ្នកប្រាជ្ញ ចំណែកឯល្បិចបង្រៀន គ្រូបង្រៀន អាចបង្កើតបានដោយខ្លួនឯង ឱ្យតែស្របតាមខ្លឹមសារមេរៀន។ មេរៀនតែមួយ ខ្លឹមសារតែមួយ តែគ្រូ អាចប្រើល្បិចបានច្រើន ដើម្បីឱ្យសិស្សចាប់បានខ្លឹមសារមេរៀននោះ ដូចជាការបង្រៀនតួអក្សរ "ក" មួយ គ្រូអាចប្រើរូបភាព ប្រើវត្ថុពិត ដើម្បីបង្ហាញសិស្សឱ្យយល់ ប្រើអក្សរចល័ត ប្រើសៀវភៅ ដើម្បី អាន ប្រើដៃដើម្បីសរសេរក្នុងខ្យល់ ឬប្រើក្ដារឆ្នួន ដើម្បីសរសេរតួអក្សរ "ក" នេះ។

## ៤-វិធីបង្រៀនផ្ទាល់

(Direct method; Méthode directe)

### ៤.១-និយមន័យ

*វិធីបង្រៀនផ្ទាល់ គឺជាវិធីមួយដែលរួមមានការធ្វើឱ្យស្គាល់ និងយល់ដឹង ដោយផ្ទាល់ទៅលើវត្ថុ និងតថភាព ដោយគ្មានអន្តរការក្នុងការពន្យល់។*

តើគ្រូ អាចបង្រៀនមេរៀនវាក្យសព្ទមួយបានឬទេ ដោយមិនមានការពន្យល់វែងអន្លាយ និងល្អិតល្អន់?

គេអាចបង្ហាញវត្ថុ ដែលជំនួសឱ្យពាក្យបាន។ គេយល់ឃើញថា វិធីនេះ ជាមូលដ្ឋានគ្រឹះនៃអព្ភន្តរញាណ ដែលគេមើលឃើញ ហើយនិយាយបានដោយខ្លួនឯង។

### ៤.២-ការប្រើប្រាស់វិធីបង្រៀនផ្ទាល់

គ្រូទាំងអស់សុទ្ធតែបានយល់ដឹង និងចេះប្រើប្រាស់វិធីនេះ។ ប៉ុន្តែវិធីនេះ ធ្វើឱ្យសិស្សយល់ពីវត្ថុទាំងឡាយបានច្បាស់លាស់។

គេប្រើប្រាស់វិធីនេះ ជាពិសេស នៅក្នុងការបង្រៀនវាក្យសព្ទ រៀនអាន និងសីលធម៌។ នាមត្រូវ បានបង្រៀនតាមការប្រើវត្ថុ ចំណែកគុណនាម ត្រូវបានបង្រៀនតាមការប្រើវត្ថុ ការធ្វើត្រាប់ ការប្រៀប ធៀប ពាក្យផ្ទុយ សទិសសព្ទ ចំណែកឯកិរិយាសព្ទ ត្រូវបានបង្រៀនតាមការប្រើសកម្មភាព និង

ឧទាហរណ៍។ ក្នុងការបង្រៀនវិធីនេះ គ្រូត្រូវជៀសវាងភាពច្របូកច្របល់ និងច្រំដែលដែលជាគ្រោះថ្នាក់នៃវិធីបង្រៀនផ្ទាល់។ គ្រូត្រូវត្រួតពិនិត្យការប្រៀបធៀបសំណួរ ចោទសួរទៅសិស្សតាមរូបភាពផ្សេងៗគ្នា ប្រើប្រាស់ពាក្យនៅក្នុងល្បះ ប្រើប្រាស់មកជាភាសាជាតិ។

### ៤.៣-សារៈសំខាន់នៃវិធីបង្រៀនផ្ទាល់

វិធីបង្រៀនផ្ទាល់ ធ្វើឱ្យការបង្រៀនមានលក្ខណៈរូបី ជៀសវាងវាទនិយម (ការនិយមថា សម្ដីសំខាន់ជាងគំនិត) ចំណេញពេលវេលា លើកសរសើរការយល់ដឹងរបស់សិស្ស ធ្វើឱ្យថ្នាក់រៀនមានភាពសកម្ម និងរស់រវើក ធ្វើឱ្យក្មេងសប្បាយរីករាយ ហើយវិធីនេះក៏បានប្រយុទ្ធនឹងភាពរាយមាយ និងការធុញទ្រាន់។

ជារួមយើងឃើញថា វិធីអព្ភន្តរញ្ញាណ និងវិធីបង្រៀនផ្ទាល់ សុទ្ធតែជាវិធីដែលគ្រូជាអ្នកដាក់ បញ្ហាដល់សិស្ស។ វាជាមូលដ្ឋាននៃចិត្តវិទ្យាទូទៅ និងចិត្តវិទ្យាកុមារ វាមានប្រសិទ្ធភាពខ្លាំងណាស់ ហើយវាបម្រើតាមសំណូមពរគោលបំណងនៃសាលាបឋមសិក្សាឱ្យបានសម្រេចតាមគោលដៅ។

ការបង្រៀនដោយប្រើវិធីផ្ទាល់នេះ គេអាចកាត់បន្ថយការនិយាយរ៉ាយរ៉ាប់វែងឆ្ងាយនាំឱ្យខាត ពេលវេលា នាំឱ្យសិស្សធុញទ្រាន់។ វាជាវិធីមួយដែលប្រើរូបភាព ឬភាពរូបី ឬអព្ភន្តរញ្ញាណមកជំនួស ដូចជា ដើម្បីពន្យល់ឱ្យសិស្សយល់អំពីសត្វក្របី។ គ្រូត្រូវរ៉ាយរ៉ាប់ពន្យល់សិស្សថា ក្របីជាសត្វជើងបួន ដូចសត្វគោ មានស្នែងដូចសត្វគោ តែស្នែងវាធំជាងជាទូទៅវាមានពណ៌ខ្មៅ។ វាជាសត្វស៊ីស្មៅជាអាហារ វាចូលចិត្តដេកក្នុងភក់ ឬក្នុងទឹកថ្លុកត្រពាំង។ ប៉ុន្តែ បើសិនជាគ្រូមានរូបភាពសត្វក្របី ឬក្របី ផ្ទាល់តែម្ដង មកបង្ហាញសិស្សនោះ ធ្វើឱ្យសិស្សយល់ភ្លាម ដោយមិនបាច់ពន្យល់ច្រើន។ វិធីនេះ ជាវិធី ដ៏សំខាន់ក្នុងការបង្រៀនភាសាខ្មែរ ជាពិសេសនៅក្នុងការបង្រៀនពាក្យ ឬអំណាន។

សរុបមក វិធីបង្រៀននេះ ជាបុព្វបុរសនៃវិធីបង្រៀនតាមរូបីកម្ម ហើយក៏ជាគ្រឹះនៃគោលវិធី សិស្សមជ្ឈមណ្ឌលសព្វថ្ងៃនេះដែរ។ ដូច្នេះ ក្នុងម៉ោងបង្រៀនសិស្ស ទាមទារឱ្យគ្រូមានសម្ភារឧបទេស សម្បូរបែប ទើបធ្វើឱ្យសិស្សចាប់អារម្មណ៍លើម៉ោងបង្រៀនរបស់ខ្លួន ហើយធ្វើឱ្យសិស្សរៀនឆាប់ចេះ ឆាប់ចាំ និងឆាប់យល់ ហើយអាចអនុវត្តបានដោយត្រឹមត្រូវផង ព្រមទាំងអាចក្រេបយកពុទ្ធិ ទៅបម្រើក្នុងជីវភាពរស់នៅបាន។

**៥-វិធីសកម្ម** ( Les méthode actives )

*វិធីសកម្ម គឺជាវិធីមួយ ដែលប្រឆាំងដាច់ខាតនឹងវិធីមួយ ដែលគេហៅថា វិធីបង្រៀនតាមប្រពៃណី គ្រូជាអ្នកបង្គាប់បញ្ជាទាំងស្រុង និងបង្រៀន តាមតែសៀវភៅ។ វិធីបង្រៀននេះ ស្តីបន្ទោសដល់ការបង្រៀនសិស្ស ដែលមានភាពអកម្ម ហើយនាំឱ្យសិស្សប្រើអស់សរីរាង្គឥន្ទ្រីយ កម្លាំងកាយ ឬ សាច់ដុំ បញ្ញា ចិត្តរបស់គេ បង្កើតឱ្យមានការសង្កេត ការធ្វើសកម្មភាព ការឆ្លុះបញ្ចាំងរិះគិត ការប្រើរូបារម្មណ៍ ហើយនិងសញ្ចេតនា។ វិធីបង្រៀនសកម្ម ធ្វើឱ្យការបង្រៀនមានភាពសកម្ម និងរស់រវើក។ វិធីបង្រៀននេះ អនុវត្តបានតាមសំណូមពរ បើសិនជាគ្រូបានគោរពតាមបុគ្គលិកលក្ខណៈសិស្សនិងបច្ចេក ទេសដ៏សំខាន់ និងគ្មានការបង្ខិតបង្ខំសិស្ស។*

*នៅក្នុងវិធីសកម្ម គ្រូត្រូវចេះ និងយល់ដឹង អំពីមូលដ្ឋានចិត្តសាស្ត្រនៃវិធីសកម្ម សកម្មភាព និង ចលនារបស់កុមារ ដែលប្រែប្រួលតាមចំណូលចិត្តកុមារ ជីវភាពពិសេសរបស់កុមារ លក្ខណៈពិសេស នៃវិធីសកម្ម ការប្រើប្រាស់វិធីសកម្ម។*

*ដើម្បីឱ្យវិធីសកម្មនេះ មានប្រសិទ្ធភាពក្នុងការបង្រៀន និងដឹកនាំសិស្ស គ្រូត្រូវអនុវត្តនូវល្បិច ផ្សេងៗទៀត ដូចជា ការសិក្សាពីមជ្ឈដ្ឋាន ការធ្វើអង្កេត និងដំណើរកម្សាន្តសិក្សា ការធ្វើកិច្ចតែងការបង្រៀន ការសិក្សាតាមរយៈការធ្វើការងារជាក្រុម ទិនានុប្បវត្តិសិក្សា និងការបោះពុម្ពប្រចាំសាលារៀន ទំនាក់ទំនង និងការផ្លាស់ប្តូរអន្តរសាលារៀន ស្វ័យគ្រប់គ្រង សមាគម និងចលនាយុវជន។ ក្រៅពីនេះ គេក៏បានបង្ហាញល្បិចខ្លះៗ ក្នុងការបង្រៀនមុខវិជ្ជាផ្សេងៗ ដូចជាតែងសេចក្តី ភាសា ប្រវត្តិវិទ្យា ភូមិវិទ្យា និងការបង្រៀនមេរៀន តាមការប្រើប្រាស់វត្ថុស្វាធ្យាយ។*

*ទាំងនេះ បញ្ជាក់ឱ្យឃើញថាវិធីបង្រៀនបែបទំនើប ដែលយកសិស្សជាមជ្ឈមណ្ឌលនៃសកម្មភាពបានចាប់ផ្តើមហើយ ថ្វីបើការប្រើប្រាស់នៅមិនទាន់បានទូលំទូលាយ មិនទាន់មានប្រសិទ្ធភាពទាំងស្រុងក្តី វាក៏ជារបត់ថ្មីមួយ ដែលខ្មែរបានទទួលនូវកំណែប្រែថ្មីសន្ធាងមួយ ក្រោយពេលខ្លួនបានទទួល ឯករាជ្យពីពួកអាណានិគមនិយមបារាំង។ វិធីសកម្មចាប់ផ្តើមសិក្សាយល់ស៊ីជម្រៅនូវមូលដ្ឋានចិត្តសាស្ត្រ របស់កុមារជាវ័យក្មេងខ្ចី ដែលត្រូវតែយកចិត្តទុកដាក់គ្រប់សកម្មភាពរបស់គេ។ កុមារចូលចិត្តធ្វើចលនា ហើយចលនានោះ ប្រែប្រួលទៅតាមចំណូលចិត្តរបស់ខ្លួន។ កុមារសប្បាយរីករាយពេលបានធ្វើសកម្មភាព បានអនុវត្តផ្ទាល់។ វា*

ភ័យខ្លាចការបង្ខំ ឱ្យនៅស្ងៀម។ ការសិក្សាមួយ ដែលមានភាពអកម្ម មិនអាចធ្វើឱ្យកុមារទទួលបានពុទ្ធិរឹងមាំទេ។ ក្រៅពីនេះ ដើម្បីសម្រេចវិធីនេះបានល្អ ក៏ត្រូវទាមទារឱ្យគ្រូមានសមត្ថភាពគ្រប់គ្រាន់ សម្ភារសិក្សា និងសម្ភារឧបទេសគ្រប់គ្រាន់ផងដែរ។

វិធីបង្រៀនទូទៅ នៅក្នុងសម័យសង្គមរាស្ត្រនិយម បានរីកចម្រើនយ៉ាងខ្លាំងក្លាហើយ ដោយសម័យនោះ ខ្មែរយើងបានទទួលឯករាជ្យ មានភាពម្ចាស់ការលើការកសាងប្រទេស។ វិធីបង្រៀនទាំងនោះ ត្រូវបានសម័យក្រោយៗទៀត យកមកសិក្សាមិនអាចរំលងចោលបានដូចជាសម័យសាធារណរដ្ឋខ្មែរ និងសម័យរាជាណាចក្រកម្ពុជាទី២ជាដើម។

ថ្វីបើក្នុងសម័យនោះ ការអនុវត្តវិធីបង្រៀនភាគច្រើនគឺប្រើគោលវិធីគ្រូមជ្ឈមណ្ឌល ដែលគ្រូជា អ្នកបង្ហាប់បញ្ញា ជាអ្នកផ្តល់ពុទ្ធិទាំងស្រុងទៅឱ្យសិស្សក្តី ក៏ការវិវត្តនៃវិធីប ង្រៀនបានកែប្រែច្រើនហើយ ជាក់ស្តែងដូចជាខ្លឹមសារវិធីសកម្ម ដែលបានដែលបានរៀបរាប់កន្លងមកហើយ។ ការសិក្សាតាមសកម្មភាពក្រុម ក៏បានចាប់ផ្តើម គឺមានន័យថា គោលវិធីសិស្សមជ្ឈមណ្ឌល បានចាប់ផ្តើមបញ្ច្រាបដល់គ្រូ បង្រៀន ហើយជាពិសេស នៅក្នុងវិធីសកម្ម ក៏មានរៀបរាប់ពីការសិក្សាស្វែងយល់ពីមជ្ឈដ្ឋាន និងការធ្វើអង្កេត និងដំណើរកម្សាន្តសិក្សាផងដែរ។ ក្រៅពីនេះ ក៏មានវិធីបង្រៀនផ្ទាល់ ដែលប្រើលក្ខណៈរូបី ឬប្រើប្រាស់រូបភាព វត្ថុពិត ។ល។ ដែលទាក់ទងដល់ចំណេះដឹង ផ្នែកអព្ភន្តរញាណ ដើម្បីអភិវឌ្ឍបញ្ញា របស់សិស្ស។

ម្យ៉ាងវិញទៀត នៅក្នុងគរុកោសល្យទូទៅ ក៏បានបង្ហាញពីវិន័យ ទណ្ឌកម្ម និងការផ្តល់រង្វាន់ ដល់សិស្សផងដែរ។ វិន័យត្រូវមានលក្ខណៈសេរី មិនត្រូវបង្ខិតបង្ខំដោយកម្លាំង តែគេត្រូវមានភាពស្រុះ ស្រួលគ្នាមានន័យថា វិន័យត្រូវឱ្យសិស្សយល់ដឹង និងព្រមទទួលដោយសុទ្ធចិត្ត។ ចំណែកទណ្ឌកម្ម មានត្រឹមការព្រមាន ការស្តីបន្ទោស ប៉ុន្តែប្រសិនបើមានកំហុសធ្ងន់ធ្ងរ មិនអាចកែកំហុសបាន គឺលុប ឈ្មោះសិស្សនោះជាស្ថាពរ។ ទណ្ឌកម្មក៏ត្រូវជៀសវាងលើរូបរាងកាយ ដូចជាវាយដោយរំពាត់ ដំបងឬ ដោយប្រើដៃជើងឱ្យឈរនៅក្នុងថ្នាក់។ល។ ផ្ទុយទៅវិញសិស្សដែលប្រឹងប្រែងរៀនសូត្រ គោរពវិន័យ ក៏ត្រូវទទួលបានរង្វាន់ដែរ ដូចជាការលើកសរសើរផ្ទាល់មាត់ ប័ណ្ណសរសើរ។ល។

## សន្និដ្ឋាន

*រួមសេចក្ដីមក វិធីបង្រៀនទូទៅក្នុងសម័យសង្គមរាស្ត្រនិយម បានឈានផុតពីភាពអវិជ្ជមាន ភាពអសកម្មទាំងឡាយ ដែលមានពីសម័យមុនៗ ដូចជាសម័យអាណានិគមនិយមបារាំង។ សាលាគរុកោសល្យដែលបានបង្កើតថ្មីៗ ក្រោយខ្មែរបានទទួលឯករាជ្យ បានចូលរួមបណ្ដុះបណ្ដាលគ្រូបឋមសិក្សានូវវិធីសាស្ត្រប ង្រៀនទំនើបនាសម័យនោះ។ ការ វិលទៅនិយមភាសាជាតិ នៅគ្រប់ភូមិសិក្សា ក៏ជាភាពវិសេសមួយ នៅក្នុងសម័យនោះដែរ។ ភាពល្អប្រសើរ ទាំងអស់ខាងលើនេះ ជនគ្រប់រូបនៅក្នុងសម័យនោះ និងសង្គមក្រោយៗមកទៀត ក៏ទទួលស្គាល់ដែរ។*

## ឯកសារយោង


១- ស៊ិន សំណាង និងយ៉ង់ ធី៖ *ប្រវត្តិនៃការអប់រំបឋម និងមធ្យមសិក្សានៅកម្ពុជាពីបុរាណ រហូតដល់បច្ចុប្បន្នកាល១៩៩៨-៩៩* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៩៩

២- ចេត្រ ឆែម៖ *សេចក្ដីណែនាំគ្រូបង្រៀនបឋមសិក្សា* រោងពុម្ពហង្សរ៉ី ភ្នំពេញ ឆ្នាំ១៩៥៥

៣- ក្រសួងអប់រំ យុវជន និងកីឡា៖ *គរុកោសល្យ* នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ ឆ្នាំសិក្សា ១៩៩៦-១០៩៧

៤- ក្រសួងអប់រំ យុវជន និងកីឡា៖ *គរុកោសល្យ* នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ ឆ្នាំសិក្សា ១៩៩៧-១០៩៨

៥- វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា៖ *គរុកោសល្យកីឡា* ឆ្នាំ២០១៥

៦- ចាន់ រដ្ឋសុផា៖ *ចិត្ត-គរុកោសល្យ* ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ២០១៣

៧- Ministère de l´Education Nationale, *Cours de perfectionnement pédagogique,* centre de préparation pédagogigue Kampong-Kantout, UNICEF, 1966.